– បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ចាម លេខ ៣៩១ អយក.បឋ.មត្ត ចុះថ្ងៃទី ០៥ ធ្នូ ឆ្នាំ ១៩៩៥ ។

– តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ខេត្តកំពង់ចាមប្តូរឈ្មោះ សាលាបឋមសិក្សាខ្នារ នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្ត កំពង់ចាម មកជា សាលាបឋមសិក្សា **ស ខេង ខ្នារ** ចាប់ពីឆ្នាំសិក្សា ១៩៩៥–១៩៩៦ នេះតទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** មន្ទីរក្រសួងអប់រំយុវជន និង កីឡា នាយកដ្ឋានចាត់តាំងនាយកដ្ឋានផែនការហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ចាម ការិយាល័យអប់រំយុវជន និង កីឡា ស្រុកត្បូងឃ្មុំ សាលាបឋមសិក្សា **ស ខេង ខ្នារ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គា សាវាន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១៧៤ អយក.ប្រក**

**ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃការប្រលង**

**សញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ ១**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៩០ នសរកត ចុះថ្ងៃទី៣១ ខែ ១០ ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ។
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២២៣៧ សជណ. អវ ចុះថ្ងៃទី ១៩-១១- ៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ ។
- បានឃើញប្រកាសក្រសួងលេខ ២៣២៩ ចុះថ្ងៃទី ១៧ .៥.៨០ ស្តីពីការ បង្កើតអោយមាន ការប្រលងសញ្ញាប័ត្រកំរិតសិក្សាទី ២ ។
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**សម្រេច**

**ប្រការ ១ :** មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ លើកទី ១ និង លើកទី ២ ត្រូវ កំណត់ ដោយក្រសួងអប់រំ យុវជន និង កីឡា ជារៀងរាល់ឆ្នាំសិក្សា ។

**ប្រការ ២ :** ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្ត – ក្រុង និង នាយកគ្រឹះស្ថានសិក្សា ដែលគ្រឹះស្ថាន ត្រូវបានកំណត់ជាមណ្ឌលប្រលងមានភារៈ រៀបចំបន្ទប់ប្រ លង សៀវភៅរូបថតបេក្ខជន បញ្ជីផ្សេង ៗ និងសំភារៈចាំបាច់សំរាប់ការ ប្រព្រឹត្តិទៅ នៃការប្រលង អោយហើយស្រេចមុន បើកសម័យប្រលង ។

- ចំពោះសាលាក្រោមឱវាទផ្ទាល់ នៃក្រសួងអប់រំយុវជន និង កីឡា នាយក គ្រឹះស្ថានសិក្សាក៏ត្រូវអនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់ នាយកដ្ឋានចំណេះទូទៅ និងមធ្យម សិក្សា ។

ប្រការ ៣ : នឹងអាចចុះឈ្មោះប្រលងលើកទី ១ បាន បេក្ខជនទាំងឡាយណាជាសិស្ស ថ្នាក់ទី ៨ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និង ឯកជនដែលបានរៀន ចំកម្មវិធីសិក្សាថ្នាក់ទី ៨ ។ ពាក្យសុំចុះឈ្មោះប្រលងមានបិទតែមត្រូវស្នើសុំ ទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា តាមឋានានុក្រម ។

ប្រការ ៤ : នឹងអាចអនុញ្ញាតអោយចូលរួមប្រលងលើកទី ២ បាន ៖

- បេក្ខជនដែលប្រលងធ្លាក់លើកទី ១ និងបានពិន្ទុសរុប នៃការប្រលង លើកទី ១ចាប់ពី ៣ / ៥ នៃពិន្ទុ ៣០ (គឺចាប់ពីពិន្ទុ ១៨ ) ឡើងទៅ ។
- បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទី ១ តែអាក់ខានពុំបានចូល រួមប្រលង ឬបានចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមាន ជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ ជាក់ស្តែង ហើយមានពាក្យសុំច្បាប់ត្រឹមត្រូវ ដោយមានការបញ្ជាក់ពីឪពុកម្តាយ ឬអាណាព្យាបាលស្នើសុំទៅរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា តាមរយៈប្រធានមណ្ឌល ដែលសាម៉ីខ្លួនត្រូវ ប្រលង ។

ប្រការ ៥ : អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ជាបេក្ខជនស្វ័យរិន បាន អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ។

ប្រការ ៦ : បេក្ខជនត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ ៖

- សលាកប័ត្រឯកត្តជនទំហំ១៥ ស.ម គុណនឹង ២១ ស.ម មានបិទរូប ថតថ្មី ថតចំពីមុខទំហំ ( ៤ ស.ម គុណ ៦ ស.ម) ចំនួន ៤ សន្លឹក ។
- រូបថត ថតថ្មី ថតចំពីមុខ (ទំហំ ៤ ស.ម គុណ ៦ ស.ម) « រូបដែល បានបិទលើសលាកប័ត្រឯកត្តជន »ចំនួន ៣ សន្លឹក ។
- បង្កាន់ដៃបង់សិទ្ធិប្រលងចំនួន ១ ច្បាប់

ប្រការ ៧ : ពាក្យសុំចុះឈ្មោះប្រលងលើកទី ១ និង លើកទី ២ នឹង ត្រូវប្រមូលផ្តុំតាម គ្រឹះស្ថានសិក្សាដែលសាមីបេក្ខជនសិក្សា ។ នាយកគ្រឹះស្ថានសិក្សា ត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរអប់រំយុវជន និង កីឡា ខេត្ត

ក្រុង ដើម្បីធ្វើការបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរ ទៅតាមមណ្ឌល និងបន្ទប់ប្រលង ។

**ប្រការ ៨ :** បេក្ខជនដែលបានប្រកាសថាត្រូវបានប្រលងលើកទី ២ មិនបាច់ដាក់ពាក្យសុំប្រលងទៀតទេ ។ មន្ទីរអប់រំយុវជន និង កីឡាខេត្ត–ក្រុងមានភារៈរៀបចំបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរទៅតាមមណ្ឌល និងបន្ទប់ប្រលង។

**ប្រការ ៩ :** បេក្ខជនស្វ័យរិនត្រូវដាក់ពាក្យសុំប្រលងដោយបញ្ជាក់សម័យប្រលង មណ្ឌលប្រលង លេខបន្ទប់ លេខតុ ដែលបានប្រលងធ្លាក់ពីឆ្នាំមុននៅតាមមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុងដែលសាមីខ្លួនបានសុំប្រលងពីឆ្នាំមុន ។ បើមានបំណងចង់ប្រលងនៅខេត្ត–ក្រុងថ្មី ដែលខ្លួនបានប្ដូរលំនៅដ្ឋាននោះត្រូវមានសេចក្ដីបញ្ជាក់លើពាក្យសុំប្រលងពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង ដែលមានសាមីខ្លួនបនប្រលងធ្លាក់ពីឆ្នាំមុន ។

**ប្រការ ១០ :** មន្ទីរអប់រំយុវជន និង កីឡា ខេត្ត–ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា «នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា» ដើម្បីពិនិត្យ និង សំរេចលើបេក្ខភាព ។

**ប្រការ ១១ :** ការក្លែងបន្លំផ្សេងៗ ដោយបេក្ខជន ត្រូវទទួលការបញ្ឈប់មិនអនុញ្ញាតអោយប្រលងចំនួន ពីរឆ្នាំ ។

**ប្រការ ១២ :** មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និង សមាជិកគណៈមេប្រយោគ មួយចំនួន តាមការចាំបាច់នៃមណ្ឌលប្រលង ។

**ប្រការ ១៣ :** សមាសភាព និងចំនួនព្រមទាំងលិខិតឧទ្ទេសនាមនៃគណៈមេប្រយោគត្រូវសំរេចដោយ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡាតាម សំណើរបស់ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

**ប្រការ ១៤ :** ចំនួនអនុរក្ស នៃមណ្ឌលប្រលង ត្រូវគិតតាមចំនួនបន្ទប់ប្រលង គុណនឹង ២,៥ ។

**ប្រការ ១៥ :** បន្ទប់ប្រលងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម ២៥ «ម្ភៃប្រាំ» នាក់ ។ បើមានបេក្ខជននៅសល់ពី ០៥ «ប្រាំ» នាក់ ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក ។

**ប្រការ ១៦ :** ប្រធានគណៈមេប្រយោគនៃមណ្ឌលប្រលងនីមួយៗ ជាអ្នកទទួលខុសត្រូវរួមចំពោះមុខក្រសួងអប់រំយុវជន និងកីឡា ក្នុងដំណើរការប្រព្រឹត្តិទៅនៃការប្រឡងទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសនៃមណ្ឌលប្រលង ។

**ប្រការ ១៧ :** ប្រធានគណៈមេប្រយោគ ត្រូវសហការ ឬធ្វើអន្តរាគមដល់អាជ្ញាធរមានសមត្ថកិច្ចនានា ដែលស្ថិតនៅជិតមណ្ឌលប្រលងក្នុងករណីចាំបាច់ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

**ប្រការ ១៨ :** មណ្ឌល ឬអនុមណ្ឌលប្រឡងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍នៃការប្រលង ប្រធានគណៈមេប្រយោគនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេប្រយោគ ទូទាំងប្រទេស ដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំយុវជន និង កីឡា ។

**ប្រការ ១៩ :** ប្រធានគណៈមេប្រយោគត្រូវ បែងចែកភារកិច្ចដល់អនុប្រធាន និង សមាជិកគណៈមេប្រយោគ អោយទទួលខុសត្រូវតាមមុខងាររៀង ៗ ខ្លួន ។

**ប្រការ ២០ :** ភារកិច្ចនៃគណៈកម្មការ អនុគណៈកម្មការ និងសមាជិកគណៈកម្មការផ្សេងៗនឹងមានចែងក្នុង សេចក្តីណែនាំមួយរបស់ក្រសួងអប់រំយុវជន និង កីឡា ។

**ប្រការ ២១ :** នៅពេលប្រលងបេក្ខជនទាំងឡាយ ត្រូវមកប្រលងអោយទាន់ពេលកំណត់ ។ ការមកប្រលងយឺតយ៉ាវលើសពី ១៥ នាទីមិនអនុញ្ញាតអោយចូលប្រឡងឡើយ ។ នៅពេលចូលប្រឡងបេក្ខជន ត្រូវមានលិខិតសំគាល់ខ្លួនដោយមានបិទរូបថត និងមានបញ្ជាក់ច្បាស់លាស់ ។ បេក្ខជនដែលគ្មានលិខិតសំគាល់ខ្លួនមិនអនុញ្ញាតអោយចូលប្រលងឡើយ។

**ប្រការ ២២ :** មិនអនុញ្ញាតអោយមានការប្រលងជំនួសគ្នាឡើយ ។

ប្រការ ២៣ : មិនអនុញ្ញាតអោយបេក្ខជនទាំងឡាយយកឯកសារនានាជាប់នឹងខ្លួនចូលក្នុងបន្ទប់ប្រឡងជាដាច់ខាត ។

ប្រការ ២៤ : បេក្ខជនទាំងឡាយត្រូវអង្គុយតាមលេខតុ របស់ខ្លួននៅគ្រប់ពេលធ្វើវិញ្ញាសា។

ប្រការ ២៥ : បេក្ខជនទាំងឡាយ ត្រូវធ្វើវិញ្ញាសាលើក្រដាសប្រលង ដែលអនុរក្សចែកអោយ ។ បេក្ខជនមិនត្រូវធ្វើសញ្ញាអ្វីលើក្រដាសប្រលងដែលនាំអោយស្គាល់ថាជាសន្លឹកកិច្ចការរបស់សាម៉ីខ្លួន ជាដាច់ខាត ។ សន្លឹកកិច្ចការប្រលងណាដែលមានសញ្ញាសំគាល់ត្រូវបានពិន្ទុសូន្យ ។

ប្រការ ២៦ : នៅពេលធ្វើវិញ្ញាសាប្រឡង មិនអនុញ្ញាតអោយបេក្ខជនលួចចម្លង ឬមានបំណងលួចចម្លងជាដាច់ខាត ។ កំហុសនៃការលួចចម្លង ឬបំណងលួចចម្លងនឹងមានចែងក្នុង អត្ថបទ មួយ ។

ប្រការ ២៧ : វិញ្ញាសា និងថេរវេលានៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាភូមិ១ លើកទី១ និង លើកទី២ ត្រូវកំណត់ដូចតទៅ ÷

១-តែងសេចក្តី រយៈពេល ២ ម៉ោង

២-គណិតវិទ្យា រយៈពេល ២ ម៉ោង

៣-សរសេរតាមអាន និងសំនួរ (សំនួររយៈពេល ៤៥ នាទី ក្រោយពីសរសេរតាមអានចប់)។

៤-រូបវិទ្យា រយៈពេល ១ ម៉ោង

៥-គីមី រយៈពេល ១ ម៉ោង

៦-សីលធម៌-ពលរដ្ឋវិជ្ជា រយៈពេល ១ ម៉ោង

៧-ជីវវិទ្យា រយៈពេល ១ ម៉ោង

៨-ភូមិវិទ្យា រយៈពេល ១ ម៉ោង

៩-ប្រវត្តិវិទ្យា រយៈពេល ១ ម៉ោង

១០-ជីវភាសា(បារាំង ឬអង់គ្លេស)រយៈពេល ១ ម៉ោង

ថេរវេលានៃការប្រព្រឹត្តិទៅនៃវិញ្ញាសា ត្រូវគិតចាប់ពីពេលចំលងប្រធានវិញ្ញាសា ឬចែកប្រធាន វិញ្ញាសាអោយបេក្ខជនចប់ ។

**ប្រការ ២៨ :** ប្រធានវិញ្ញាសាប្រលង ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី ៨ នៃមធ្យមសិក្សាកំរិត១ ។ វិញ្ញាសា ទាំងអស់ជាវិញ្ញាសាសរសេរ ។

**ប្រការ ២៩ :** ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬតាក់តែងដោយក្រសួង អប់រំ យុវជន និងកីឡា ។

**ប្រការ ៣០ :** ប្រធានវិញ្ញាសាទាំងឡាយដែលជ្រើសរើស ឬតាក់តែងរួចហើយ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត និងប្រថាប់ត្រាហើយបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតមណ្ឌលប្រលងអោយថែរក្សាទុក ៤៨ ម៉ោងមុនពេលប្រកាសចាប់ផ្ដើមប្រលង ។

**ប្រការ ៣១ :** អាជ្ញាធរមានសមត្ថកិច្ចដែលថែរក្សាប្រធានវិញ្ញាសាទាំងនោះ ត្រូវប្រគល់អោយប្រធានគណៈមេប្រយោគចំពោះមុខសមាជិក នៅថ្ងៃចាប់ផ្ដើមការប្រលងមួយម៉ោងមុនពេលបើកសម័យប្រលង ។

**ប្រការ ៣២ :** ការប្រគល់អោយ និង ការទទួលយកវិញនូវប្រធានវិញ្ញាសាប្រលង ត្រូវមានការទទួលខុស ត្រូវទាំងសងខាងដោយមានកំណត់ហេតុជាផ្លូវការផង ។

**ប្រការ ៣៣ :** ប្រធានវិញ្ញាសានីមួយៗត្រូវមានចំនួនស្មើនឹងចំនួនបន្ទប់ប្រលង ។ បើខ្វះត្រូវចំលងបន្ថែមបង្គ្រាប់ភ្លាម លើកលែងតែប្រធានវិញ្ញាសាជីវភាសាដែលមានចំនួនស្មើនឹងចំនួនបេក្ខជន ។

**ប្រការ ៣៤ :** វិញ្ញាសានីមួយៗ ពុំមានមេគុណទេ ហើយត្រូវកំណត់ពិន្ទុដូចតទៅ ÷

| | |
|---|---|
| ១–តែងសេចក្ដី | ត្រូវបានពិន្ទុពី ០ ដល់ ១០ |
| ២–គណិតវិទ្យា | ត្រូវបានពិន្ទុពី ០ ដល់ ១០ |
| ៣–សរសេរតាមអាន និងសំនួរ | ត្រូវបានពិន្ទុពី ០ ដល់ ១០ |
| ៤–រូបវិទ្យា | ត្រូវបានពិន្ទុពី ០ ដល់ ៥ |
| ៥–គីមី | ត្រូវបានពិន្ទុពី ០ ដល់ ៥ |
| ៦–សីលធម៌–ពលរដ្ឋវិជ្ជា | ត្រូវបានពិន្ទុពី ០ ដល់ ៥ |
| ៧–ជីវវិទ្យា | ត្រូវបានពិន្ទុពី ០ ដល់ ៥ |
| ៨–ភូមិវិទ្យា | ត្រូវបានពិន្ទុពី ០ ដល់ ៥ |

៩–ប្រវត្តិវិទ្យា ត្រូវបានពិន្ទុពី ០ ដល់ ៥

១០–ជីវភាសា( បារាំងឬអង់គ្លេស)ត្រូវបានពិន្ទុពី ០ ដល់ ៥

វិញ្ញាសានីមួយៗ នឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខជនអវត្តមាន ឬបេក្ខជនដែលមិនបានប្រគល់ វិញ្ញាសាដល់គណៈមេប្រយោគ ។

**ប្រការ ៣៥ :** បេក្ខជនទាំងឡាយ អាចជ្រើសរើសយកភាសាតែមួយប៉ុណ្ណោះ ក្នុងចំណោមភាសាបារាំង ឬភាសាអង់គ្លេសនៅពេលធ្វើវិញ្ញាសាជីវភាសា ។

**ប្រការ ៣៦ :** ពិន្ទុជីវភាសានឹងគិតយកតែពិន្ទុដែលបេក្ខជនធ្វើបានលើសពី ២,៥០ ទៅបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេង ៗ ទៀត ។

ឧទាហរណ៍ :

១-បើបេក្ខជនណាម្នាក់ធ្វើវិញ្ញាសាភាសាបារាំង ឬភាសាអង់គ្លេសបាន ៤ ពិន្ទុ បេក្ខជននោះនឹងត្រូវបាន ១,៥០ ពិន្ទុសំរាប់បូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេងៗទៀត ។

២-បើបេក្ខជនណាម្នាក់ធ្វើវិញ្ញាសាភាសាបារាំង ឬភាសាអង់គ្លេសបានពិន្ទុចាប់ ពី ២,៥០ ចុះ បេក្ខជននោះត្រូវចាត់ទុកថាបានពិន្ទុសូន្យ ចំពោះវិញ្ញាសាជីវភាសា ។

**ប្រការ ៣៧ :** វិញ្ញាសាសរសេរតាមអានត្រូវគិតជាពីរផ្នែកគឺ ពិន្ទុសរសេរតាមអាន ៥ ពិន្ទុ ពិន្ទុសំណួរ ៥ ពិន្ទុ។ សំនួរសរសេរតាមអានត្រូវអានអោយបេក្ខជនសរសេរ តែមិន ត្រូវសរសេរនៅលើក្តារខៀនឡើយ ។

**ប្រការ ៣៨ :** «ពាក្យ »សរសេរខុសនៅក្នុងសរសេរតាមអានត្រូវយកកំហុសតាមតារាងអត្រាកំណែដែលគណៈមេប្រយោគបានសំរេច ។

**ប្រការ ៣៩ :** វិញ្ញាសាសរសេរនីមួយៗ ត្រូវកែដោយសមាជិកកំណែពីរនាក់ជាដាច់ខាតតាមអត្រាកំណែដែលគណៈមេប្រយោគបានសំរេច ។

**ប្រការ ៤០ :** នឹងត្រូវប្រកាសថាប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ បេក្ខជនទាំងឡាយណាដែលបានពិន្ទុសរុបចាប់ពី ៣០ ឡើងទៅ ដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយលើក លែងតែវិញ្ញាសាជីវភាសា ។ ក្នុងករណីចាំបាច់

គណៈមេប្រយោគអាចធ្វើសំរង់អោយជាប់បន្ថែម ក្រោយពីមានការយល់ព្រមពីក្រសួងអប់រំយុវជន និងកីឡា និងតាមសំណើរបស់គណៈមេប្រយោគហើយត្រូវមានកំណត់ហេតុបញ្ជាក់ច្បាស់លាស់ពីសំរង់បន្ថែម ។ បេក្ខជនស្វ័យរិនមិនធ្វើសំរង់អោយជាប់បន្ថែមឡើយ ។

**ប្រការ ៤១ :** គណៈមេប្រយោគមណ្ឌលប្រលងនីមួយ ៗ ត្រូវប្រជុំពិភាក្សារួមដើម្បីសំរេចលទ្ធផលនៃការប្រលង ។ កំណត់ហេតុ និងបញ្ជីចាំបាច់នានាភ្ជាប់មកជាមួយត្រូវបញ្ជូនទៅក្រសួងអប់រំយុវជន និង កីឡា (នាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា) ជាពីរ ច្បាប់ ដើម្បីសុំសេចក្តីយល់ព្រម ។

**ប្រការ ៤២ :** និទ្ទេសដែលត្រូវកំណត់មានដូចតទៅ ÷

| | | | | |
|---|---|---|---|---|
| ចាប់ពីពិន្ទុសរុប | ៣០,០០ | ទៅពិន្ទុសរុប | ៣៨,៧៥ | និទ្ទេសមធ្យម |
| ចាប់ពីពិន្ទុសរុប | ៣៩,០០ | ទៅពិន្ទុសរុប | ៤៧,៧៥ | និទ្ទេសល្អបង្គួរ |
| ចាប់ពីពិន្ទុសរុប | ៤៨,០០ | ឡើងទៅ | | និទ្ទេសល្អ |

**ប្រការ ៤៣ :** នឹងត្រូវប្រកាសថាត្រូវបានប្រលងលើកទី ២ បេក្ខជនទាំងឡាយណាដែលមិនបានប្រកាស ថាប្រលងជាប់លើកទី ១ ហើយបានពិន្ទុសរុបចាប់ពី ១៨ ឡើងទៅដោយមិនគិតពិន្ទុសូន្យចំពោះ មុខវិជ្ជាណាមួយ ។

**ប្រការ ៤៤ :** បទបញ្ញត្តិ ស្តីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ពីមុន ៗ ទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤៥ :** ប្រធានមន្ទីរ និងប្រធាននាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា និង អង្គភាពពាក់ព័ន្ធនៃ ក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀង ៗ ខ្លួន ដើម្បីអោយបានសំរេចនូវប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តូច ឡាយ

* * *